# Advancing Green Investments

*Support to Help Your Business Secure Green Financing*

**Many businesses have strong commercial potential and are well-positioned to access concessional green financing. The missing piece is often the technical documentation that financiers require, such as feasibility studies, energy assessments, or green certifications.**

**The Cambodia Australia Partnership for Resilient Economic Development (CAPRED) – Australia's flagship economic development program in Cambodia – can help cover the cost of this technical work.**

## Available support

CAPRED works with eligible businesses to meet green finance requirements by directly funding approved technical services up to US$50,000.

This support helps your business:

- **Build a strong case for green investment**
- **Reduce assessment costs**
- **Deliver financier-ready technical documents**



## Technical services

The program funds a range of technical services, including:

- Technical and financial feasibility assessments
- Green certifications and credentials (e.g. EDGE, LEED, etc.)
- Monitoring, reporting and verification system establishment
- Energy audits and efficiency baselines
- Climate risk and impact assessments
- Environmental, social and gender assessments

## Eligible projects

The program supports businesses pursuing commercial green investments across:

- **Energy efficiency**
- **Sustainable agriculture**
- **Renewable energy**
- **Green buildings**
- **Waste management, recycling and circularity**
- **Climate-resilient water supply**

## How it works

**Connect**
Speak to CAPRED about your proposed green investment

**Define**
Coordinate with your financier to identify green financing requirements

**Activate**
Apply for CAPRED funding to access technical expert support services

**Finalise**
Submit completed documentation to your financier

**Interested?** Contact us: climate@capred.org

Australian Aid

CAPRED

# ជំនួយគាំទ្រដើម្បីជំរុញការវិនិយោគបៃតង

*«គាំទ្រអាជីវកម្មរបស់លោកអ្នកដើម្បីទទួលបានហិរញ្ញប្បទានបៃតង»*

អាជីវកម្មជាច្រើនមានសក្តានុពលខ្ពស់ និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីទទួលបានហិរញ្ញប្បទានសម្បទានបៃតង ប៉ុន្តែបញ្ហាប្រឈមដែលកើតមានជាញឹកញាប់គឺ ការខ្វះខាតឯកសារបច្ចេកទេស ដែលតម្រូវដោយអ្នកផ្តល់ហិរញ្ញប្បទានបៃតង ដូចជា របាយការណ៍សិក្សាសមិទ្ធិលទ្ធភាព របាយការណ៍វាយតម្លៃការប្រើប្រាស់ថាមពល ឬវិញ្ញាបនបត្របៃតង ជាដើម។ កម្មវិធីភាពជាដៃគូ កម្ពុជា អូស្ត្រាលី សម្រាប់ ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED) ដែលជាកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចឈានមុខគេរបស់ប្រទេសអូស្ត្រាលីប្រចាំនៅកម្ពុជា អាចជួយដោះស្រាយលើបញ្ហានេះបាន តាមរយៈការជួយគាំទ្រ ការចំណាយលើការរៀបចំឯកសារបច្ចេកទេសទាំងនេះ។

## ការគាំទ្រដែលផ្តល់ជូន

CAPRED ផ្តល់ជំនួយលើការចំណាយសេវាកម្មបច្ចេកទេស មានតម្លៃរហូតដល់ ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក សម្រាប់អាជីវកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបំពេញលក្ខខណ្ឌបច្ចេកទេសតម្រូវដោយអ្នកផ្តល់ហិរញ្ញប្បទានបៃតង។

ការគាំទ្រនេះអាចជួយអាជីវកម្មលោកអ្នកក្នុងការ៖

- កសាងអំណះអំណាងនៃគុណប្បសម្បត្តិបៃតងរបស់គម្រោងការវិនិយោគរបស់លោកអ្នក
- កាត់បន្ថយការចំណាយលើការបំពេញលក្ខខណ្ឌបច្ចេកទេសនានា
- ផ្តល់នូវឯកសារបច្ចេកទេសដែលត្រឹមត្រូវស្របតាមការរំពឹងទុករបស់អ្នកផ្តល់ហិរញ្ញប្បទាន



## ជំនួយគាំទ្របច្ចេកទេស

CAPRED ផ្តល់ជំនួយលើការចំណាយសេវាកម្មបច្ចេកទេសជាច្រើន រួមមាន៖

- ការវាយតម្លៃសមិទ្ធលទ្ធភាពបច្ចេកទេស និងសេដ្ឋកិច្ច
- វិញ្ញាបនបត្របៃតងផ្សេងៗ (ដូចជា EDGE ឬ LEED)
- ការរៀបចំបង្កើតប្រព័ន្ធ ឬយន្តការត្រួតពិនិត្យ រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV)
- ការធ្វើសវនកម្ម និងប្រសិទ្ធភាពថាមពល
- ការវាយតម្លៃហានិភ័យ និង ផលប៉ះពាល់អាកាសធាតុ
- ការវាយតម្លៃ និងផែនការលើកកម្ពស់បរិស្ថាន សង្គម និងយេនឌ័រ

## គម្រោងដែលអាចទទួលបានការគាំទ្រ

CAPRED គាំទ្រអាជីវកម្មដែលវិនិយោគលើគម្រោងបៃតងក្នុងវិស័យដូចខាងក្រោម៖

- **ប្រសិទ្ធភាពថាមពល**
- **កសិកម្មប្រកបដោយនិរន្តរភាព**
- **ថាមពលកកើតឡើងវិញ**
- **អគារបៃតង**
- **ការគ្រប់គ្រង កែច្នៃ និងប្រើប្រាស់សំណល់**
- **ការផ្គត់ផ្គង់ទឹកដែលមានភាពធន់នឹងអាកាសធាតុ**

## របៀបស្នើសុំការគាំទ្រ

| **ជជែក៖** | **កំណត់៖** | **អនុវត្ត៖** | **សម្រេច៖** |
| --- | --- | --- | --- |
| ពិភាក្សាជាមួយតំណាង CAPRED លើផែនការគម្រោងវិនិយោគបៃតងរបស់លោកអ្នក។ | ពិភាក្សាជាមួយអ្នកផ្តល់ហិរញ្ញប្បទានដើម្បីកំណត់ពីលក្ខខណ្ឌបច្ចេកទេសនានា ដើម្បីទទួលបានហិរញ្ញប្បទានសម្បទានបៃតង។ | បំពេញពាក្យស្នើសុំជំនួយពី CAPRED ដើម្បីទទួលបានការគាំទ្រលើចំណាយសេវាបច្ចេកទេសរបស់អ្នកជំនាញ។ | ដាក់ឯកសារសម្រេច ជូនអ្នកផ្តល់ហិរញ្ញប្បទានដើម្បីបំពេញលក្ខខណ្ឌដែលបានកំណត់។ |

**បើលោកអ្នកមានចំណាប់អារម្មណ៍** សូមទាក់ទងមកយើងខ្ញុំតាមរយៈ៖ climate@capred.org